# ៧ មករា ១៩៧៩
# សញ្ញាយ័នៃយួនូបនីយកម្ម

ថ្ងៃ៧មករា១៩៧៩ គឺជា ព្រឹត្តិការណ៍មរតកនៃថ្ងៃ១៧មេសា១៩៧៥ និង ថ្ងៃ២ធ្នូ ១៩៧៨ ដែលចងជាសង្វាក់បន្តបន្ទាប់គ្នានៅក្នុងបរិបទនយោបាយមួយច្បាស់លាស់ ។ ព្រឹត្តិការណ៍ទាំងនេះ បានហុចផលវិបាកដ៏ធ្ងន់ធ្ងរអោយប្រជាជាតិជាតិខ្មែរ ។ ប្រជាជនខ្មែរត្រូវរស់នៅក្នុងមហាសោក នាដ្យកម្មគ្មានទីបញ្ចប់ ។ សង្គមជាតិខ្មែរ ត្រូវបែកបាក់គ្នាកាន់តែខ្លាំង ដែលបណ្ដាលអោយវាកាន់តែចុះឱនថយទៅៗ ដូចយើងឃើញសព្វថ្ងៃនេះ ។

តើ៧មករា១៩៧៩ ជាសញ្ញាយ័ស្ពាពររបស់យួន ?

ផែនការណ៍យូរអង្វែងរបស់មេដឹកនាំយួន (មីញ-ម៉ាង, ហូ-ជីមិញ, ផាំ-វ៉ាន់ដុង, …) : « ការបំបាត់ពូជសាសន៍ខ្មែរ និង ការវាតទឹកដីនិយម » បានដក់ជាប់នៅក្នុងចិត្តគំនិតរបស់អ្នកដឹកនាំយួន និង ប្រជាជនយួនផងដែរ ។ គួរកត់សម្គាល់ដែរថា ប្រជាជនយួន ជាជនជាតិចូលចិត្តចំណាកស្រុកដើម្បីស្វែងរកតំបន់សេដ្ឋកិច្ចងាយស្រួល ដូចនេះជាកត្តាសំខាន់មួយក្នុងការបំពេញមហិច្ឆតារបស់មេដឹកនាំរបស់គេ ទោះជាដោយសម្បជញ្ញៈឬអសម្បជញ្ញៈក្តី ។ ដូចនេះសង្វាក់នៃព្រឹត្តិការណ៍នយោបាយទាំងអំបាលមាណបានបញ្ជាក់ពី scénarios សំខាន់ៗ ដែលមេដឹកនាំយួនបានតាក់តែងឡើង ។ ដើម្បីសម្រេចផែនការណ៍យូរអង្វែងខាងលើនេះ មេដឹកនាំយួនបានដកបទពិសោធ សង្កេតមើល និង រៀបចំឧបាយកលយ៉ាងណាអោយខ្មែរគ្នាឯងជាអ្នកដើរតួនាទីជំនួសគេ ។

គួររំឭកពីថ្ងៃ១៧មេសា១៩៧៥ នាពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានឡើងកាន់អំណាចក្រោមផ្លាក « អង្គការលើ » ដែលនៅពីក្រោយនេះប្រកបដោយអាថ៌កំបាំង (សូមអានសៀវភៅ « អង្គការជាអ្នកណា ? » របស់អ្នកស្រីគីម-ធីអុយ, ឯកសារ ប្រវត្តិសាស្ត្ររបស់លោកសោម-សេក កុមា..។ល។ ) ។ ប្រវត្តិសាស្ត្រ បានបង្ហាញថា ខ្មែរក្រហមជាអទិផលរបស់យួនកុំម្មុយនិស្ត ហើយជ័យជម្នះ១៧មេសាឆ្នាំ១៩៧៥នេះក៏ជាអន្តរាគមន៍របស់យួនដែរ ។ ដោយមានការអនុញ្ញាត និង ការគាំទ្ររបស់នរោត្តម-ស៊ីហនុ កងទ័ពយួនបានតាំងជម្រកនៅក្នុងប្រទេសខ្មែរតាំងពីទសវត្ស៦០ម្ល៉េះ(១) ។ ប្រជាជនខ្មែរដែលរស់នៅតាមបណ្ដោយព្រំដែនខាងកើតបានរងទុក្ខលំបាក ដោយសារតែវត្តមាននៃកងទ័ពយួនដែល កាន់តែកើនច្រើនឡើងៗ ប្រជាជនខ្មែរចាប់ផ្ដើមនិរាសព្រាត់ប្រាសដោយសារ សង្គ្រាមយួន ដែលចេះតែរីករាលដាលដោយវត្តមានទព័យួននៅក្នុងទឹកដីខ្មែរ ។ ដូចនេះកងទព័យួនរង់ចាំតែឱកាសដើម្បីបើក

យុទ្ធនាការវាយប្រហារខ្មែរស្របតាមផែនការណ៍យូរអង្វែងរបស់គេ ។ វិបត្តិសង្គមកាន់តែធ្ងន់ធ្ងរក្រោយឆ្នាំ១៩៧០ នាពេលដែលស៊ីហានុបានបើកភ្លើងបៃតងអោយកងទព័យួនធ្វើយុទ្ធនាការ ។ នៅតាមទីប្រជុំជន មានអំពើភេរវកម្ម វិទ្ធង្សនា និង វិច្ឆេទកម្មជាច្រើនដែលត្រូវបានបង្កឡើងដោយពួកយួន ដែលចេះនិយាយភាសាខ្មែរតែប៉ុន្មានម៉ាត់ប៉ុណ្ណោះថា « ធ្វើការអោយស៊ីហានុ » ។

ផលប្រយោជន៍នៃការប្រល័យពូជសាសន៍ខ្មែរ បានទៅអ្នកណា ?

តាមធម្មតាគេធ្វើអ្វីៗដើម្បីផលប្រយោជន៍ ។ សហរដ្ឋអាមេរិកទៅធ្វើសង្គ្រាមនៅអ៊ីរ៉ាក់មកពីរំពឹងផលចំណេញ ។ ចិនកុំម្មុយនិស្តធ្វើបដិវត្តន៍វប្បធម៌ ដោយមានសម្លាប់ជនជាតិចិនអស់ប្រមាណ ៣% ក៏ដើម្បីផលចំណេញ ដូចយើងឃើញវឌ្ឍនភាពរបស់គេសព្វថ្ងៃ ។

តើការ កាប់សម្លាប់ខ្មែរអស់ប្រមាណ ៤០% បានផលចំណេញអ្វីដល់អ្នកធ្វើ ?

តាមតក្កកម្មខាងលើ គឺប្រាកដជាបានមែន ។ ការពិត អ្នកដែលបានរៀបចំធ្វើការប្រល័យពូជសាសន៍ខ្មែរបានទទួលផលប្រយោជន៍ ដូចបំណងគេដែលបានគ្រោងទុកជាមុនអញ្ចឹង ។ ពួកយួនកុំម្មុយនីស្តបានរៀបចំកម្មវិធីបំបាត់ដាន ដើម្បីបង្ហាញភ្នែកប្រជាជនខ្មែរអោយឃើញថា « ខ្មែរជាអ្នកសម្លាប់ខ្មែរគ្នាឯង » ។ ដោយសារពួកយួនកុំម្មុយនីស្តធ្លាប់រស់នៅជាមួយខ្មែរក្រហមយូរមកហើយ ការធ្វើវិទ្ធង្សនាដោយផ្ទាល់ឬដោយប្រយោល គឺជាការងាយស្រួលមួយ ។ ពួកខ្មែរក្រហម តែងតែងប់ងល់នឹងជយ័ជម្នះ នឹងអំណាច មិនបានប្រមើលដឹងពីកម្លាំងសម្ងាត់យួនដែលបង្កប់នៅក្នុងជួររបស់ខ្លួន ។ មូលហេតុមួយនៃការជម្រុញអោយមានការកាប់សម្លាប់នេះ គឺមកពីមេដឹកនាំខ្មែរក្រហមនៃរបបកម្ពុជាប្រជាធិតេយ្យ បដិសេធ ការចុះហត្ថលេខាលើ « សន្ធិសញ្ញាមិត្តភាព និង សហប្រតិបត្តិការ រវាងកម្ពុជានិងវៀតណាម » (ដែលក្រោយមកសន្ធិសញ្ញានេះត្រូវបានចុះ ហត្ថលេខានៅឆ្នាំ១៩៧៩ ដោយហេង-សំរិននៃរបបសាធារណរដ្ឋប្រជាមានិតុកម្ពុជា) ។ សន្ធិសញ្ញានេះ ជាកិច្ចសន្យាការបង់ថ្លៃទីមួយ នៃអន្តរាគមន៍យោធានាពេលសង្គ្រាម ដើម្បីសម្រួលដល់អតិក្រមយួនទូបនីយកម្ម ។ ដូចនេះ បើរបបកម្ពុជាប្រជាធិបតេយ្យមិនព្រមបង់ថ្លៃនេះ គេត្រូវតែប្តូររបបផ្សេង ដែលមានបំណែកស្រាប់នៅក្នុងខ្មែរក្រហម ។